EMBASSY OF JAPAN IN CAMBODIA

# PRESS RELEASE

No. 16PR-26/EoJ                                                    25 March 2026

## Japan Provides US$493,765 for Improving Primary Education in Kampong Thom Province

The Government of Japan will provide US$493,765 for the recipient organization under the framework, *the Grant Assistance for Japanese NGO Projects*. The Grant Contract was signed today between H.E. Mr. UENO Atsushi, Ambassador Extraordinary and Plenipotentiary of Japan to the Kingdom of Cambodia, and the representative of the recipient, to carry out the following project:

‘Improve primary education quality and advance children’s learning and teaching in rural Cambodia (IMPACT)’
(US$493,765)
Recipient: World Vision Japan

This project seeks to improve the early educational learning outcomes of children in Kampong Thom province. The project’s key components include strengthening teachers' capabilities in targeted schools through teacher training, implementing remedial classes based on learning assessments, and improving the learning environment.

*The Grant Assistance for Japanese NGO Projects* started in Cambodia in 2002 to support activities by Japanese NGOs to help Cambodia's reconstruction and development efforts at the grassroots level. Since 2002, the Government of Japan has provided over US$60 million for over 170 projects, mainly in the field of primary education, health, agriculture and mine clearance in Cambodia.

---

*Embassy of Japan in Cambodia*
*Tel: 023-217-161*
*Email:* eco.jpn@pp.mofa.go.jp
*Website:* *http://www.kh.emb-japan.go.jp*

**ស្ថានទូតជប៉ុន**
**ប្រចាំប្រទេសកម្ពុជា**

# សេចក្តីប្រកាសព័ត៌មាន

លេខ 16PR-26/EoJ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៦

## ជប៉ុនផ្តល់ថវិកាចំនួន ៤៩៣,៧៦៥ ដុល្លារអាមេរិក សម្រាប់កែលម្អការអប់រំថ្នាក់បឋមសិក្សានៅខេត្តកំពង់ធំ

រដ្ឋាភិបាលជប៉ុន នឹងផ្តល់ថវិកាសរុបចំនួន **៤៩៣,៧៦៥ ដុល្លារអាមេរិក** ដល់ស្ថាប័នទទួលជំនួយមួយក្រោមគ្រោងការណ៍ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយ **ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងអ្នកតំណាងស្ថាប័នទទួលជំនួយ សម្រាប់អនុវត្តគម្រោងខាងក្រោម៖

**<u>កែលម្អគុណភាពអប់រំថ្នាក់បឋមសិក្សា និងលើកកម្ពស់ការរៀន និងបង្រៀនរបស់កុមារនៅជនបទក្នុងប្រទេសកម្ពុជា (ថវិកាចំនួន ៤៩៣,៧៦៥ ដុល្លារអាមេរិក)</u>**

**<u>ស្ថាប័នទទួលជំនួយ៖ អង្គការទស្សនៈពិភពលោកជប៉ុន</u>**

គម្រោងនេះមានគោលបំណងកែលម្អលទ្ធផលសិក្សាផ្នែកអប់រំកុមារតូចក្នុងខេត្តកំពង់ធំ។ ធាតុផ្សំសំខាន់ៗរបស់គម្រោងរួមមានការពង្រឹងសមត្ថភាពគ្រូបង្រៀននៅក្នុងសាលាគោលដៅ តាមរយៈការបណ្តុះបណ្តាលគ្រូ ការអនុវត្តថ្នាក់បំប៉ងដោយផ្អែកលើការវាយតម្លៃការសិក្សា និងការកែលម្អបរិយាកាសសិក្សា។

ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជាក្នុងឆ្នាំ២០០២ ដើម្បីគាំទ្រដល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីជួយដល់ការអភិវឌ្ឍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅកម្រិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២ មក រដ្ឋាភិបាល ជប៉ុនបានផ្តល់ថវិកាជាង ៦០លាន ដុល្លារអាមេរិក ដល់គម្រោងចំនួន ១៧០ ដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតបឋមសិក្សា វិស័យសុខាភិបាល វិស័យកសិកម្ម និងសកម្មភាពបោសសម្អាតមីនក្នុងប្រទេសកម្ពុជា។

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរសព្ទ៖ ០២៣-២១៧-១៦១*

*អ៊ីម៉ែល៖ eco.jpn@pp.mofa.go.jp*

*គេហទំព័រ៖ http://www.kh.emb-japan.go.jp*

# សុន្ទរកថារបស់ ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី
# ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យា
# ផ្តល់ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន

ថ្ងៃពុធ ទី២៥ ខែមីនា ឆ្នាំ២០២៦

**គម្រោង៖ «កែលម្អគុណភាពអប់រំថ្នាក់បឋមសិក្សា និងលើកកម្ពស់ការរៀន និងបង្រៀនរបស់កុមារនៅជនបទក្នុងប្រទេសកម្ពុជា»**

**ស្ថាប័នអនុវត្ត៖ អង្គការទស្សនៈពិភពលោកជប៉ុន (World Vision Japan)**

- លោកបណ្ឌិត កាន់ ពុទ្ធី ប្រធាននាយកដ្ឋានបឋមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា
- លោកស្រី Chiba Mina ប្រធានគម្រោងអង្គការទស្សនៈពិភពលោកជប៉ុន
- លោក លោកស្រី ភ្ញៀវកិត្តិយស ទាំងអស់ជាទីមេត្រី!

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដែលបានរៀបចំពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុននៃឆ្នាំសារពើពន្ធ២០២៥។

ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន ដែលហៅថា "អ៊ិនរ៉េន" បានចាប់ផ្តើមតាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រដល់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមរបស់ពួកគេនៅក្នុងប្រទេស ឬតំបន់កំពុងអភិវឌ្ឍ។ ក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ ស្ថានទូតជប៉ុនបានផ្តល់ជំនួយជាង ១៧០គម្រោង នៅក្នុងប្រទេសកម្ពុជាតាមរយៈកម្មវិធីនេះ ហើយគម្រោងទាំងនេះបានចូលរួមចំណែកដោយផ្ទាល់ក្នុងការកែលម្អគុណភាពជីវិតរបស់ប្រជាជនកម្ពុជា។

ខ្ញុំសូមជម្រាបជូនដោយសង្ខេបអំពី ដែលយើងបានចុះហត្ថលេខានាថ្ងៃនេះ៖

រដ្ឋាភិបាលជប៉ុននឹងផ្តល់ថវិកា ប្រមាណ ៤៩ម៉ឺនដុល្លារអាមេរិកដល់អង្គការអង្គការទស្សនៈពិភពលោក (World Vision Japan )សម្រាប់អនុវត្តគម្រោងរបស់អង្គការនៅក្នុងខេត្តកំពង់ធំ។

ចាប់តាំងពីឆ្នាំ ១៩៩៦ អង្គការទស្សនៈពិភពលោកជប៉ុនបាននិងកំពុងអនុវត្តសកម្មភាពទាក់ទងនឹងសុខភាព អនាម័យ ការអប់រំ និងការលើកកម្ពស់ប្រាក់ចំណូល តាមរយៈការអភិវឌ្ឍន៍សហគមន៍នៅក្នុងខេត្តនានានៃប្រទេសកម្ពុជា។ យើងសូមសម្តែងនូវការគោរពដ៏ជ្រាលជ្រៅរបស់ជាថ្មីម្តងទៀតចំពោះសមទ្ធផលដ៏ធំធេងជាច្រើនឆ្នាំរបស់អង្គការ។

សម្រាប់គម្រោងដែលបានចុះហត្ថលេខានាថ្ងៃនេះ អង្គការទស្សនៈពិភពលោកជប៉ុននឹងផ្តល់ជំនួយគាំទ្រដល់សាលារៀនគោលដៅចំនួន ៦ ក្នុងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ក្នុងគោលបំណងលើកកម្ពស់គុណភាពអប់រំ។ ជាពិសេស អង្គការនឹងដោះស្រាយបញ្ហាប្រឈមក្នុងវិស័យអប់រំ ដូចជា ការខ្វះខាតឱកាសសម្រាប់ការបណ្តុះបណ្តាលគ្រូកំពុងបង្រៀន និងកង្វះលទ្ធភាពទទួលបានសម្ភារៈបង្រៀន ក៏ដូចជាឧបករណ៍ឌីជីថលនានា ព្រមទាំងគាំទ្រដល់ការពង្រឹងសមត្ថភាពគ្រូបង្រៀន តាម រយៈការអនុវត្តជាចម្បងនូវកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន និងការអនុវត្តមេរៀនបន្ថែមដោយផ្អែកលើការវាយតម្លៃការសិក្សា។ ជាងនេះទៅទៀត ដើម្បីឆ្លើយតបទៅនឹងភាពចាស់ទ្រុឌទ្រោមនៃបរិក្ខារសាលារៀន និងស្ថានភាពកង្វះនៃសម្ភារៈសិក្សា អង្គការក៏នឹងកែលម្អបរិយាកាសសិក្សា តាមរយៈការជួសជុល និងរៀបចំសម្ភារៈបរិក្ខារថ្មីៗ។ តាមរយៈកិច្ចខិតខំប្រឹងប្រែងទាំងនេះ យើងរំពឹងថានឹងអាចធ្វើឲ្យប្រសើរឡើងនូវលទ្ធផលសិក្សាលើមុខវិជ្ជាមូលដ្ឋានសម្រាប់កុមារដែលរស់នៅតំបន់ជនបទ ហើយអាចរួមចំណែកកាត់បន្ថយគម្លាតក្នុងការសិក្សានៅក្នុងប្រទេសកម្ពុជា។

នាពេលថ្មីៗនេះ ប្រទេសកម្ពុជាបាននិងកំពុងអភិវឌ្ឍយ៉ាងឆាប់រហ័ស។ ទោះបីជាយ៉ាងណា ខ្ញុំក៏ទទួលស្គាល់ថានៅតែមានបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយ ដើម្បីកែលម្អគុណភាពជីវិតរបស់ប្រជាជន មិនត្រឹមតែក្នុងវិស័យអប់រំប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្នុងការអភិវឌ្ឍន៍សង្គមរួមមានការកាត់បន្ថយភាពក្រីក្រ បញ្ហាហេដ្ឋារចនាសម្ព័ន្ធ សុខាភិបាល និង បរិស្ថានជាដើមផងដែរ។។ក្រោមភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយជប៉ុន-កម្ពុជា រដ្ឋាភិបាលជប៉ុន និងស្ថានទូតជប៉ុនប្រចាំនៅកម្ពុជា មានបំណងបន្តកិច្ចសហប្រតិបត្តិការជាមួយអង្គការក្រៅរដ្ឋាភិបាលជប៉ុន ដើម្បីគាំទ្រដល់ការដោះស្រាយបញ្ហាប្រឈមនានានៅកម្ពុជា ។

ជាទីបញ្ចប់ ខ្ញុំសង្ឃឹមថាគម្រោងដែលបានចុះហត្ថលេខានាថ្ងៃនេះដំណើរការទៅដោយរលូន និងទទួលបានភាពជោគជ័យនាពេលអនាគត។ ហើយខ្ញុំក៏សូមជូនពរ លោក លោកស្រី ដែលមានវត្តមាននៅទីនេះ សូមមានសុខភាពល្អ សុភមង្គល និង សូមឱ្យមិត្តភាពជប៉ុន-កម្ពុជាកាន់តែរីកចម្រើន។

សូមអរគុណ។